**ខណៈដែលករណីកូវីឌចុះថយ គម្រោងបើកសាលានឹងធ្វើទៅតាមការគ្រោងទុក**

សហគមន៍សាលារៀនក្នុងក្រសួងអប់រំឡុងប៊ីចជាទីមេត្រី,

ខណៈដែលតួរលេខករណីកូវីឌ១៩កំពុងមានការថយចុះ ហើយមានបុគ្គលិកសាលាកាន់តែច្រើននាក់បានទទួលការចាក់ថ្នាំបង្ការរោគ ក្រសួងអប់រំឡុងប៊ីចមានគម្រោងបើកសាលារៀនជាដំណាក់ៗនៅថ្ងៃទី២៩មីនាដដែល។

អត្រាករណីកូវីឌនៅក្នុងខោនធីឡូសអ៊ុនជើលេសមានកំរិត៧ករណីលើ១០០០០០នាក់នៅក្នុងសប្តាហ៍នេះ ជាការបន្តចុះថយជាច្រើនក្នុងរយៈពេលមួយខែកន្លងមកនេះ ដែលអនុញ្ញាតឱ្យយើងបើកសាលារៀនវិញតាមការគ្រោងទុក។

**កម្រិតអន្តរមត្តេយ្យដល់ទី៥ (TK-5)**
ដូចដែលបានប្រកាសកន្លងមក សិស្សដែលត្រឡប់ទៅរៀននៅសាលានៅថ្ងៃទី២៩ខែមិនាគឺសិស្សពីកំរិតថ្នាក់អន្តរមត្តេយ្យ (TK) ដល់ថ្នាក់ទី៥ ដែលមាតាបិតាបានជ្រើសរើសតារាងវេលាសិក្សាប្រភេទហាយប្រ៊ីឌ(ពាក់កណ្តាលនៅសាលាពាក់កណ្តាលនៅផ្ទះ)។ គ្រូបង្រៀននឹងវិលត្រឡប់ទៅសាលាវិញនៅថ្ងៃទី២២ខែមីនាដើម្បីរៀបចំថ្នាក់រៀនសម្រាប់សិស្សដែលវិលត្រឡប់មករៀននៅសាលា ស្របពេលដែលការរៀនសូត្រតាមអនឡាញនឹងបន្តធ្វើទៀត។ សាលារៀនបានរៀបត្រៀមបំរុងសម្រាប់សិស្សដោយរៀបចំគម្លាតត្រឹមត្រូវរវៀងតុសិស្ស កែលំអរប្រព័ន្ធចម្រោះខ្យល់ គ្រោងសម្រាប់ច្រកចេញចូលដែលមានសុវត្ថិភាព ហើយនិងរៀបចំឱ្យមានបន្ទប់ពិសេសមួយ CARE Room នៅរាល់សាលារៀន សម្រាប់ដាក់សិស្សនៅពេលដែលពួកគេមានរោគសញ្ញាកូវីឌពេលនៅសាលា។ ក្នុងរយៈពេលពីរបីសប្តាហ៍ទៅមុននេះ សាលារៀននឹងបន្តតែស្តមើលប្រព័ន្ធសុវត្ថិភាពរបស់គេ រួមទាំងការលាងសម្អាតគ្រឿងឧបករណ៍ និងប្រដាប់ស្ទង់កំដៅខ្លួនពីចម្ងាយ ដែលប្រើនៅគ្រប់ច្រកចូល។

មាតាបិតានិងអាណាព្យាបាលសិស្សសាលាបឋមសិក្សាត្រូវបានអញ្ជើញឱ្យនិយាយជាមួយកូនរបស់គាត់អំពីការផ្លាស់ប្តូរនេះដែលនឹងចាប់ផ្តើមនៅចុងខែមីនា។ នៅថ្ងៃព្រហស្បតិ៍ក្នុងសប្តាហ៍នេះ បន្ថែមពីលើសារសម្រាប់សហគមន៍នេះ គ្រួសារសិស្ស TK-5 នឹងទទួលព័ត៌មានសំខាន់ៗពីសាលារៀនរបស់កូនគាត់។ ព័ត៌មាននេះនឹងមានពន្យល់ពីវិធិការសុខភាពនិងសុវត្ថិភាពដែលនឹងប្រើទូទាំងក្រសួងអប់រំទាំងមូល ហើយនិងព័ត៌មានផ្ទាល់របស់សាលារៀន។

**កំរិតអនុវទ្យាល័យនិងវិទ្យាល័យ**

សន្មតថាខោនធីឡូសអ៊ុនជើលេសស្ថិតនៅក្នុងស្ថានភាពតាមលក្ខណៈវិនិច្ឆ័យសុខភាពសាធារណៈជនរបស់រដ្ឋ ការវិលត្រឡប់ទៅរៀននៅសាលាតាមតារាងវេលាហាយប្រ៊ីឌរបស់អនុវិទ្យាល័យនិងវិទ្យាល័យ នឹងចាប់ផ្តើមកាលវេលាក្រោមនេះដូចដែលបានប្រកាសកន្លងមក។

- ថ្ងៃទី១៩ខែមេសា - ថ្នាក់ទី១២
- ថ្ងៃទី២០ខែមេសា - ថ្នាក់ទី៦ដល់ថ្នាក់ទី៨
- ថ្ងៃទី២៦ខែមេសា - ថ្នាក់ទី៩ដល់ទី១១

គ្រូបង្រៀនសាលាអនុវិទ្យាល័យនិងវិទ្យាល័យនឹងត្រឡប់ទៅសាលារៀនវិញនៅថ្ងៃទី១២ខែមេសាដើម្បីរៀបចំថ្នាក់រៀនសម្រាប់សិស្សដែលវិលត្រឡប់មករៀននៅសាលា ស្របពេលដែលការរៀនសូត្រតាមអនឡាញនឹងបន្តធ្វើទៀត។ ដូចគ្នានឹងសាលាបឋមសិក្សាដែរ គ្រួសារសិស្សសាលាអនុវិទ្យាល័យនិងសាលាវិទ្យាល័យនឹងទទួលព័ត៌មានពីសាលារៀនរបស់កូនគាត់ផ្ទាល់ នៅពេលដែលថ្ងៃសិស្សវិលត្រឡប់ទៅសាលារៀនវិញកាន់តែឈានចូលជិតមកដល់។ សម្រាប់ពេលបច្ចុប្បន្ននេះ មាតាបិតាសិស្សសាលាអនុវិទ្យាល័យនិងវិទ្យាល័យគប្បីចូលរួមក្នុងការប្រជុំតាមអនឡាញដែលសាលារៀនរបស់កូនគាត់បានកំពុងធ្វើ ដើម្បីផ្តល់ព័ត៌មានដល់គ្រួសារអំពីកម្មវិធីសិក្សា ហើយសូមកុំភ្លេចបំពេញសំណួរអំពីជំរើសរបស់មាតាបិតាថាតើគាត់នឹងឱ្យកូនទៅរៀននៅសាលាផ្ទាល់ឬបន្តឱ្យកូនគាត់រៀនតាមអនឡាញ។

## គម្រោងសុខភាពនិងសុវត្ថិភាព

សុវត្ថិភាពរបស់បុគ្គលិកនិងសិស្សានុសិស្សគឺជាអាទិភាពជំបូងរបស់ក្រសួងអប់រំ។ គម្រោងបើកសាលានិងគម្រោងសុវត្ថិភាពលើការរាតត្បាតសាកលកូវិឌ១៩ របស់ក្រសួងអប់រំឡុងប៊ីច LBUSD នៅតែមានសម្រាប់សាធារណៈជន នៅក្នុងវែបសាយ lbschools.net/coronavirus ។ នៅថ្ងៃច័ន្ទក្នុងសប្តាហ៍នេះ ក្រសួងអប់រំឡុងប៊ីចនឹងដាក់ប្រគល់ ទៅដល់ក្រសួងសុខាភិបាលប្រចាំទីក្រុងឡុងប៊ីច នូវឯកសារដែលចាំបាច់ សម្រាប់ការអនុញ្ញាតឱ្យបើកសាលាបាន។ ការឆ្លើយតបត្រូវបានរំពឹងថានឹងបានទទួលមកវិញក្នុងអំឡុងរយៈពេល៧ថ្ងៃ ពីក្រសួងសុខា ភិបាលប្រចាំទីក្រុងឡុងប៊ីច។

ក្រសួងអប់រំឡុងប៊ីច បន្តសហការជាមួយក្រសួងសុខាភិបាលក្រុងឡុងប៊ីច ក្នុងការផ្តល់ការចាក់ថ្នាំបង្ការរោគដល់បុគ្គលិកសាលា។ មកទល់នឹងថ្ងៃសៅរ៍នេះ គ្រប់បុគ្គលិកសាលារៀនទាំងអស់នឹងបានទទួលឱកាស ចាក់ថ្នាំបង្ការរោគកូវិឌ ហើយដល់ចុងខែនេះ គ្រប់បុគ្គលិកទាំងអស់នឹងបានទទួលឱកាសចាក់ថ្នាំបង្ការរោគលើកទីពីររាល់គ្នា។

បន្ទាប់ពីអស់រយៈពេលជិតមួយឆ្នាំនៃការរៀនតាមអនឡាញនិងភាពលំបាកទាំងឡាយដោយសាររោគរាតត្បាតសាកល យើងមានសេចក្តីរីករាយនឹងចែករំលែកនូវការលូតលាស់ប្រសើរឡើង ស្របពេលដែលយើងធ្វើការឆ្ពោះទៅកាន់ភាពធម្មតាវិញ។ សូមអរគុណដល់ការគាំទ្រជាបន្តរបស់លោកអ្នក។

ដោយក្តីស្មោះចំពោះ,

Jill

បណ្ឌិត Jill Baker អគ្គនាយកសាលារៀន